## *សង្ខេបវេយ្យាករណ៍ថ្នាក់ទី៩

» ពាក្យឫសមានពីរ
- ពាក្យឫសពីរមែនបង្កើតពាក្យដ៏ទៃទៀត
- ពាក្យឫសដែលជាកំណើត

» សព្វនាម
- សព្វនាមបុរិសៈ (ខ្ញុំ, គាត់, អក្ន, នាង, វា ...)
- សព្វនាមឈ្នាប់ (ដែល)
- សព្វនាមសំនួរ (នរណា, នរណាខ្លះ, អ្នកណា ...)
- សព្វនាមកម្មសិទ្ធ (របស់ខ្ញុំ, របស់អ្នក, របស់វា.)
- សព្វនាមឆ្លុះ (ខ្លួនខ្ញុំផ្ទាល់, ខ្លួនអ្នកផ្ទាល់ ...)
- សព្វនាមចង្អុល (នោះ, នេះ ...)
- សព្វនាមមិនច្បាស់ (អ្នកណាខ្លះ, នរណាខ្លះ ...)

» នាម
- នាមសាធារណ៍ (វត្ត, សាលា, ផ្លូវ, ខេត្ត ...)
- នាមអសាធារណ៍ (ប៊ិច, សៀវភៅ ...)
- នាមរូបី (តុ, ផ្កា, ក្តាខៀន, កង់ ...)
- នាមអរូបី (ភាពផ្អែម, ជូ, ចត់, សមត្ថភាព ...)
- នាមជីវចល (កង់, ម៉ូតូ, ឡាន ...)
- នាមអជីវចល (ផ្ទះ, មន្ទីរពេទ្យ, វត្ត ...)
- នាមករណ៍ (ចំណាំ, ទំនិញ, ដំណើរ ...)
- នាមការក៍ (អ្នកក្រ, ឈ្លួញ, អ្នកល្បី ...)
- សមូហនាម (ហ្វូងគោ, ចង្កោមសោ ...)
- នាមផ្សំ (ន + ន, ន + កិ, ន + គុ ...)
- នាមរនាប់ (ផ្លូន, ឡូរ, តម្បូរ, គូ, គូប ...)

» គុណនាម
- គុណនាមសំណួរ (ប៉ុន្មាន, អី, ណាមួយ ...)
- គុណនាមកម្មសិទ្ធ (ខ្ញុំ, វា, នាង, ឯង ...)
- គុណនាមចង្អុល (នេះ, នោះ, ទាំងនេះ ...)
- គុណនាមចំនួន(រៀប, រាប់ ...)
- គុណនាមមិនច្បាស់ (ទាំងអស់, ...)
- គុណនាមប្រក្រតី (ធំ, តូច, ខ្ពស់ ...)

» គុណកិរិយា
- គុណកិរិយាកាល (យប់, ថ្ងៃ ...)
- គុណកិរិយាបំនែប (យឺតៗ, ប្រាវ ...)
- គុណកិរិយាកន្លែង (ខាងលិច, ខាងក្រោម ...)
- គុណកិរិយាបរិមាណ (ច្រើន, តិច ...)
- គុណកិរិយាសំនួរ (ហេតុដូចម្តេច, អង្កាល់ ...)

» កិរិយាស័ព្ទ
- កិរិយាសុទ្ធ (ដើ, ដេក ...)
- កិរិយាក្លាយ (ផ្តេក, ផ្តួល ...)
- កិរិយាហេតុ (...)
- កិរិយាសកម្ម (ជីក, ទៅ, ជិះ ...)
- កិរិយាអកម្ម (ដើរ, រត់ ...)

» ឈ្នាប់
- ឈ្នាប់ចង (និង, ប៉ុន្តែ, តែឬ, ឬក៏, ហើយ ...)
- ឈ្នាប់ឃ្លា (ទោះបី, ថ្វីបើ, ព្រោះ, ពីព្រោះ ...)

» ថ្នាក់ពាក្យ
- នាម
- សព្វនាម
- គុណនាម
- កិរិយាស័ព្ទ
- គុណកិរិយា
- ចំណាងផ្នាក់
- ឈ្នាប់
- ឧទានសព្ទ

## *និយមន័យ

### ⊠ ថ្នាក់ពាក្យ

- សព្វនាមៈ ជាពាក្យជំនួសន័យអោយនាមបាននិយាយរួចម្តងហើយ។
- នាមៈ ជាពាក្យសំរាប់សម្គាល់មនុស្ស សត្វ វត្ថុ រុក្ខជាតិ។
- គុណនាមៈ ជាពាក្យសំដែងលក្ខណះរបស់នាម។
- គុណកិរិយាៈ ជាពាក្យសំរាប់បំពេញលក្ខណះអោយកិរិយា។
- កិរិយាស័ព្ទៈ ជាពាក្យសំដែង នូវអំពើរ។
- ឈ្នាប់ៈ ជាពាក្យសំគាល់ទំនាក់ទំនងគ្នា រវាង ពាក្យ និង ពាក្យ, ឃ្លា និង ឃ្លា, ល្បះ និង ល្បះ។
- ចំណាងផ្នាក់ៈ ជាពក្យចំណាងសំរាប់ប្រើក្នុងកន្សោមនាមបង្កើតបានជាកន្សោមមានផ្នាក់។
- ឧទានស័ព្ទៈ ជាពាក្យគ្រាប់សូរ្យធម្មជាតិ ឬ ពាក្យសំដែងនូវអារម្មណ៍។

### ⊠ នាម

- នាមសាធារណ៍ៈ ជានាមសំរាប់សំដែងនូវឈ្មោះមនុស្ស សត្វ វត្ថុ ទីកន្លែងទូទៅដោយមិនចំពោះ។
- នាមអសាធារណ៍ៈ ជានាមសំរាប់សំដែងនូវឈ្មោះមនុស្ស សត្វ វត្ថុ ទីកន្លែងទូទៅដោយ ចំពោះ មិន ទូទៅ។
- នាមរូបីៈ ជានាមមានរូបមើលឃើញ និង ចាប់បាន។
- នាមអរូបីៈ សំដៅទៅលើនាមមើល មិនឃើញ ចាប់មិនបាន។
- នាមជីវចលៈ សំដៅទៅលើនាមដែលមានជីវិត។
- នាមអជីវចលៈ សំដៅទៅលើនាមដែលឥត ជីវិត។
- នាមករណ៍ៈ សំរាប់សំដែងនូវសភាពលក្ខណះអ្វីមួយហើយវាមានកំណើតមកពី កិរិយាស័ព្ទ គុណនាម ពាក្យបន្ថែមដើម និង ពាក្យបន្ថែមចុង។
- នាមការក៍ៈ សំរាប់សំដែងអ្នកធ្វើអំពើ ឬ មានសភាព លក្ខណះ ណាមួយហើយវាមានកំណើតមកពី កិរិយាស័ព្ទ គុណនាម នាម។
- សមូហនាមៈ សំដៅទៅលើ ពួក ឬ ក្រុម។
- នាមផ្សំៈ ជានាមច្រើនរួមគ្នាដែលកើតចេញពី ន + ន, ន + កិ, ន + គុ។
- នាមរនាប់ៈ គឺជានាមនៅខាងស្តាំគុណនាមរាប់។

### ⊠ គុណនាម

- គុណនាមសំនួរៈ សំរាប់សួរកសភាពលក្ខណះ។
- គុណនាមកម្មសិទ្ធៈ សំរាប់ប្រាប់ម្ចាស់កម្មសិទ្ធ។
- គុណនាមចង្អុលៈ សំរាប់បង្ហាញទីជិត ឬ ឆ្ងាយ។
- គុណនាមចំនួនៈ សំរាប់ប្រាប់បរិមាណ តាមលំដាប់លំដោយ។
- គុណនាមមិនច្បាស់ៈ សំរាប់បង្ហាញសភាពមិនច្បាស់ មិនជាក់លាក់។
- គុណនាមប្រក្រតីៈ សំរាប់ប្រាប់លក្ខណះរបស់មនុស្ស។

⌧ **គុណកិរិយា**

- គុណកិរិយាកាលៈ ប្រាប់កាលរបស់កិរិយា...។
- គុណកិរិយាបំនែបៈ ប្រាប់បែបបទនៃអំពើរបស់កិរិយា។
- គុណកិរិយាកន្លែងៈ ប្រាប់ទីតាំងនៃការធ្វើអំពើរបស់កិរិយា។
- គុណកិរិយាបរិមាណៈ សំរាប់បញ្ជាក់ពីទំហំ និង ចំនួន។
- គុណកិរិយាសំនួរៈ សំរាប់សួររកបំនែប ហេតុ កាល បរិមាណ។

⌧ **កិរិយាស័ព្ទ**

- កិរិយាស័ព្ទសុទ្ធៈ ជាកិរិយាសំដែងនូវអំពើរបស់ប្រធានដែលធ្វើ។
- កិរិយាក្លាយៈ
- កិរិយាហេតុៈ ជាកិរិយាដែលសំដែងអំពើរបស់ប្រធានគ្រាន់តែជាហេតុដើម ចង់ប៉ុន្នោះ។
- កិរិយាសកម្មៈ ជាកិរិយាដែលត្រូវការកម្មបទ។
- កិរិយាអកម្មៈ ជាកិរិយាដែលមិនត្រូវការកម្មបទ។

⌧ **ឈ្នាប់**

- ឈ្នាប់ចងៈ ជាពាក្យចំណងសំរាប់សម្គាល់ទំនាក់ទំនងល្បះ និង ល្បះ ឬ ជាតុផ្សេងៗនៅក្នុងល្បះ។
- ឈ្នាប់ឃ្លាៈ ជាពាក្យចំណងសំរាប់សម្គាល់ទំនាក់ទំនងឃ្លា និង ឃ្លាសម្រាប់ បង្កើតឃ្លារណប។ ឈ្នាប់ឃ្លាមានៈ
  - ➢ ប្រើជាគុណប្រធាន ឬ គុណបទ (ជា ថា)
  - ➢ ហេតុ (ព្រោះ ពីព្រោះ)
  - ➢ បំណង (ដើម្បី)
  - ➢ លក្ខខណ្ឌ (បើ ប្រសិនបើ)
  - ➢ ទំនាស់ (ទោះបី ថ្វីត្បិតតែ)
  - ➢ កាល (លុះ កាលណា)

*** ប្រភេទរឿង**

- »រឿងពិត
  - អាលីយូហ្សា
  - ព្រះនាងឥន្ទ្រទេវី
  - លោកប៉ាស្ទ័រ
  - លិនខល
  - កុមារញ៉ូតុណ
  - កំណើតទូរស័ព្ទ
- »ប្រលោមកថា
  - កុលាបប៉ៃលិន
  - មាលាដួងចិត្ត
  - សឹមបទ្បាន
  - ផ្កាស្រពោន
  - សុជាត
  - មហាចោទល់ដែន
- »តំនាលកថា
  - ធនញ្ជ័យ
  - ចចក និង រាជសី
  - មាយាស្ត្រី
- »ចលនាអក្សរសិល្ប៍
  - ខេមរនិយម
  - បរទេសនិយម
  - ព្រាហ្មនិយម
  - ពុទ្ធនិយម

∇ ឈ្មោះអ្នកនិពន្ធរឿង

- លោក ញ៉ុក ថែម — កុលាបប៉ៃលិន (ចៅចិត្រ ឃុននារី)
- លោក នូ ហាច — មាលាដួងចិត្ត (ទីឃាវុធ ចន្ទមុនី)
  ផ្កាស្រពោន (ប៊ុនធឿន វិជារី)
- លោក រឹម គីម — សុជាត (សុជាត ម៉ានយ៉ាន)
- លោក សាង សាវ៉េត — មហាចោទល់ដែន (មានន្ទ ទេវី)
- លោក អ៊ឹម ថុក — ស៊ឹមអ្នកបទ្បាន (ស៊ឹម,....)
- លោក ឈឹម ស៊ុមន៍ — ព្រះវេស្សន្តរ
- ភិក្ខុ សោម — ទុំទាវ (ទុំ ទាវ)

# *មែកធាងនៃអរិយធម៌

- អរិយធម៌
  - វប្បធម៌
    - ចំណេះដឹង
      - ជំនឿ សាសនា
      - វិទ្យាសាស្ត្រ
      - សិលធម៌
    - ការកំណត់ផ្សាយ
      - ភាសា អក្សរ សញ្ញា
      - អក្សរសាស្ត្រ អក្សរសិល្ប៍
      - សិល្បៈ ពត៌មាន
    - ការអនុវត្តន៍
      - ទំនៀមទំលាប់ ប្រពៃណី
      - ការអប់រំ ច្បាប់
      - កីឡា ល្បែងកំសាន្ត
  - សង្គមធម៌
    - គ្រឿងសង្គម
      - ប្រដាប់រស់នៅ
      - វិធីបច្ចេកទេស
      - មុខរបរ
    - សង្គមវិធី
      - សេដ្ឋកិច្ច
      - សង្គមកិច្ច
      - នយោបាយ
    - សង្គមប្រភេទ
      - វណ្ណៈសង្គម
      - អង្គការសង្គម
      - អង្គការរដ្ឋ

រៀបរៀងដោយ ក្រុម យុវសិស្សនៃ វិទ្យាល័យ បរេល